**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

- សាលក្រមលេខ ៣៥ "ជ១" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣
- សំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣
- សំណុំរឿងស៊ើបសួរលេខ ៦៦៨ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣
- សំណុំរឿងជំនុំជម្រះលេខ ១៥៤៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៩:០០នាទី នៅសាលសវនាការទី៦ ជាន់ទី៥ ដោយមានសមាសភាព៖

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក [redacted] អនុប្រធាន នៃសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះមុនអង្គសេចក្តីលើពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្នចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ របស់លោក [redacted] ម៉ាឌី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WEIDONG ស្ថិតក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៨១៨ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] WEIDONG ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មុខរបរ អ្នកទេសចរណ៍ កាន់ លិខិតឆ្លងដែនលេខ [redacted] ទីកន្លែងកំណើត ប្រទេសចិន ទីលំនៅបច្ចុប្បន្នស្នាក់នៅ បុរីអ័រគីដេ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] MING "រ" ម្តាយឈ្មោះ [redacted] YUE HUA "រ" នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣២៨ "រ" ដ.ឃ.ដ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ។ (PJ)

-ដោយមានលោក [redacted] ម៉ាឌី ជាមេធាវីការពារសិទ្ធិ ។

-ដោយមានលោក [redacted] សេង ជាអ្នកបកប្រែភាសាចិន ។

ជាប់ចោទពីបទ៖ **បើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា** ប្រព្រឹត្តនៅចំណុចមុខមណ្ឌលសុខភាពទឹកថ្លា លើមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**<u>អង្គហេតុនៃរឿងមានដូចតទៅ៖</u>**

កាលពីថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ២០២៣ នៅវេលាម៉ោង ២១ និង ២០ នាទី នៅត្រង់ចំណុចមុខ មណ្ឌលសុខភាពទឹកថ្លា លើមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងរវាងរថយន្តម៉ាក AIPHARD ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AQ-1325 បើកបរ ដោយឈ្មោះ [redacted] WEIDONG ភេទ



Scanned with CamScanner

ប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន បានធ្វើដំណើរតាមបណ្តោយផ្លូវមហាវិថី សហព័ន្ធរុស្ស៊ី ទិសដៅពីលិចទៅកើត លុះបើក មកដល់ចំណុចកើតហេតុខាងលើ បានបត់ឆ្វេង ក៏បុកជាមួយម៉ូតូ មួយគ្រឿងម៉ាក SUZUKI SMASH ពណ៌ស ពាក់ស្លាក លេខ ភ្នំពេញ 1CS6159 បើកបរដោយឈ្មោះ [redacted] ប៊ុនហេង ភេទប្រុស អាយុ៤៤ឆ្នាំ ដែលធ្វើដំណើរស្របទិសគ្នាបណ្តាល ឱ្យអ្នកបើកបរម៉ូតូឈ្មោះ [redacted] ប៊ុនហេង រងរបួសធ្ងន់ សម្រាកនៅមន្ទីរពេទ្យព្រះកុសុមៈ រួចបញ្ជូនទៅព្យាបាលនៅប្រទេសវៀតណាម ក៏ទទួលមរណៈភាពនៅប្រទេសវៀតណាម តែម្តង ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៦១៧ អ.យ.ជ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២០៧៣ (វ) ដ.ង/២៣ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ ពាក្យសុំកូនក្តីនៅក្រៅឃុំបណ្តោះអាសន្ន របស់លោកមេធាវី ហេង ម៉ាឌី ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] WEIDONG បានឆ្លើយនាពេលសវនាការថា៖ ពេលនេះខ្ញុំមានបញ្ហាសុខភាព ដែលត្រូវទៅព្យាបាល ម្យ៉ាងខ្ញុំបាទបានសងសំណងទៅគ្រួសារជនរងគ្រោះរួចរាល់ហើយ មួយទៀតខ្ញុំបាទគ្រាន់តែជាអ្នកស៊ីឈ្នួលបើករថយន្តឱ្យគេតែប៉ុណ្ណោះ ហេតុនេះស្នើសុំតុលាការសម្រេចឱ្យខ្ញុំបាទបាននៅក្រៅឃុំដើម្បីទៅរកស៊ីចញ្ចឹមគ្រួសារ ។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WEIDONG បានថ្លែងការណ៍ថា៖ សព្វថ្ងៃកូនក្តីខ្ញុំកំពុងឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ។ ខ្ញុំបាទស្នើសុំឱ្យតុលាការមេត្តាសម្រេចដាក់ឱ្យកូនក្តីខ្ញុំបាទ បាននៅក្រៅឃុំជាបណ្តោះអាសន្នសិន ដោយមូលហេតុថា ក្រោយពេលកើតហេតុ ភាគីកូនក្តីខ្ញុំបាទបានទំនាក់ទំនងជាមួយគ្រួសារជនរងគ្រោះដើម្បីបង្ហាញពីឆន្ទៈ នៃការដឹងកំហុស និងជួយចេញសំណងរដ្ឋប្បវេណីទៅគ្រួសារជនរងគ្រោះរួចរាល់ផងដែរ ហើយគ្រួសារជនរងគ្រោះក៏បានអធ្យាស្រ័យលើកលែងកំហុស និងបានដកពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ឈប់ប្តឹងមកលើកូនក្តីខ្ញុំបាទផងដែរ ។ ម្យ៉ាងបច្ចុប្បន្ននេះកូនក្តីខ្ញុំបាទមានបញ្ហាសុខភាព ដែលចាំបាច់ត្រូវការពិនិត្យ និងព្យាបាលសុខភាពឱ្យបានត្រឹមត្រូវនៅមន្ទីរពេទ្យ ។ ហើយការស្នើសុំនេះ កូនក្តីខ្ញុំបាទ ធានាអះអាងថាគាត់មានទីតាំង មានអាសយដ្ឋានស្នាក់នៅច្បាស់លាស់ត្រឹមត្រូវគាត់មិនគេចវេសពីការកោះហៅរបស់តុលាការទេ ។

ហេតុនេះខ្ញុំបាទស្នើសុំលោកចៅក្រម ពិចារណាលើមូលហេតុខាងលើដើម្បីសម្រេច និងអនុញ្ញាតឱ្យកូនក្តីខ្ញុំបាទបាននៅក្រៅឃុំតាមការស្នើសុំដោយក្តីអនុគ្រោះ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] WEIDONG ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ បើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ។ តាមការអះអាងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឃើញថា មានហេតុផលសមរម្យ ដែលតុលាការគប្បីសម្រេចអនុញ្ញាតឱ្យជនជាប់ចោទបានៅក្រៅឃុំជាបណ្តោះអាសន្ន ។ ហេតុនេះ តំណាងអយ្យការ យល់ស្របថា គប្បីអនុញ្ញាតឱ្យជនជាប់ចោទបាននៅក្រៅឃុំបណ្តោះអាសន្នតាមពាក្យសុំ ។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

បើផ្អែកតាមមាត្រា២០៣ គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព។ ដូចដែលមូលហេតុដែលបានដេញដោលនាពេលសវនាការ ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទសូមស្នើសុំតុលាការ មេត្តាសម្រេចដោះលែងកូនក្តីខ្ញុំបាទឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយផ្អែកតាមមូលហេតុដូចខាងក្រោម៖

១-កូនក្តីខ្លួនមានបញ្ហាសុខភាព ដែលត្រូវការការព្យាបាល និងពិនិត្យពីមន្ទីរពេទ្យជំនាញ និងបានរកប្រាក់ចញ្ចឹមគ្រួសារ ។

២-កូនក្តីខ្ញុំក៏បានដឹងនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត និងបានសម្របសំរួលសងសំណងរដ្ឋប្បវេណីទៅគ្រួសារជនរងគ្រោះ ហើយគ្រួសារជនរងគ្រោះក៏បានដាក់ពាក្យសុំដកពាក្យបណ្តឹង២៤ ខែមេសា ឆ្នាំ២០២៣ ហើយគ្មានមូលហេតុណាមួយដែលកូនក្តីនាងខ្ញុំត្រូវធ្វើការគាបសង្កត់លើសាក្សី ឬជនរងគ្រោះឡើយ ។

៣-ចំពោះចំណុចភស្តុតាង និងតម្រុយជាសម្ភារៈនេះ ត្រូវបានតុលាការធ្វើការបញ្ចប់ការស៊ើបអង្កេតនិងបិទការស៊ើសួររួចទៅហើយ រហូតដល់សំណុំរឿងនេះត្រូវបានបញ្ជូនមកជំរះដែរ។

៤-កូនក្តីខ្ញុំបាទមានទីលំនៅច្បាស់លាស់ អាចបង្ហាញខ្លួនតាមការកោះហៅរបស់តុលាការ និងអាចអនុវត្តតាមកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា និងព្រមទាំងមានមេធាវីការពារក្តីផងដែរ។

៥-ចំពោះការអនុញ្ញាតិឱ្យកូនក្តីនាងខ្ញុំនៅក្រៅឃុំបណ្តោះអាសន្ន មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងមិនបង្កឱ្យមានភាពច្របូកច្របល់ដែលបណ្តាលមកពីបទល្មើសនេះទេ ព្រោះថាសំណុំរឿងក្តីនេះ ត្រូវបានចៅក្រមស៊ើបសួរធ្វើការស៊ើបសួរចប់សព្វគ្រប់ហើយរហូតបញ្ជូនមកជំនុំជំរះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សំណូមពរសុំឱ្យលោកចៅក្រមមេត្តាអនុញ្ញាតិឱ្យកូនក្តីនាងខ្ញុំបាននៅក្រៅឃុំបណ្តោះអាសន្ន។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ របស់លោក [redacted] ម៉ានី មេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ [redacted] WEIDONG បានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលជនជាប់ចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំ ។

២-តាមសេចក្តីថ្លែងការណ៍នាពេលសវនាការ និង សេចក្តីសន្និដ្ឋានការពារ របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទតុលាការយល់ឃើញថា ការលើកឡើងរបស់លោកមេធាវីមាន មូលហេតុដែលគប្បីពិចារណា ដោយហេតុថាតាមស្ថានភាពបច្ចុប្បន្នរបស់ជនជាប់ចោទឈ្មោះ [redacted] WEIDONG ជនជាប់ចោទរូបនេះមានបញ្ហាសុខភាព ហើយការនៅក្រៅឃុំរបស់ជនជាប់ចោទមិនប៉ះពាល់ដល់មាត្រា២០៣ នោះទេ ជនជាប់ចោទសុំនៅក្រៅឃុំ ហើយគ្រួសាររបស់ជនរងគ្រោះក៏បានដកពាក្យបណ្តឹង ព្រមទាំងបានទទួលសំណងពីជនជាប់ចោទរួចរាល់ផងដែរ ហេតុនេះតុលាការគប្បីពិចារណាចំពោះស្ថានភាពនេះ ។



Scanned with CamScanner

៣-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានលើកឡើងអំពីមូលហេតុមួយចំនួនដូចមានក្នុងសេចក្តីសន្និដ្ឋានប្តឹងសុំខាងលើអំពីការអនុញ្ញាតអោយជនជាប់ចោទបាននៅក្រៅឃុំបណ្តោះអាសន្ន តុលាការយល់ឃើញថាការសន្និដ្ឋាននោះមានមូលហេតុ និងមូលដ្ឋាន គ្រប់គ្រាន់ដែលគប្បីពិចារណា ។

៤-តាមចម្លើយរបស់ជនជាប់ចោទ, ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ, ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គប្បីតុលាការពិចារណាលើសំណើរសុំរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងយោបល់របស់តំណាងអយ្យការដើម្បីអោយជនជាប់ចោទអាចនៅក្រៅឃុំជាបណ្តោះអាសន្ន ។ តែគប្បីដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

## ហេតុដូច្នេះសម្រេច

១/-បង្គាប់ឱ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្នលើជនជាប់ចោទ ឈ្មោះ [redacted] WEIDONG ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន ដែលជាប់ចោទពីបទ បើកបរបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ប្រព្រឹត្តនៅចំណុចមុខមណ្ឌលសុខភាពទឹកថ្លា លើមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិ មាត្រា៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២/-បង្គាប់ឱ្យប្រធានពន្ធនាគាររាជធានីភ្នំពេញ(PJ) ដោះលែងជនជាប់ចោទឈ្មោះ [redacted] WEIDONG ។ ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀត។

៣/-ដាក់ជនជាប់ចោទឈ្មោះ [redacted] WEIDONG ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយត្រូវគោរពនិងអនុវត្តនូវកាតព្វកិច្ចដូចខាងក្រោម ៖

ក-មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជាដោយគ្មានការអនុញ្ញាតពីតុលាការ

ខ-មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីតុលាការ

គ-ត្រូវចូលបង្ហាញខ្លួនតាមការកោះហៅរបស់តុលាការ៕

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] WEIDONG និងលោក [redacted] ម៉ាឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

រក្សាសិទ្ធិឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**
---|---
ហត្ថលេខានិងត្រា [redacted] | ហត្ថលេខានិងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃច័ន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted] ទំព័រ

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner